# I - ឯកសារគណៈរដ្ឋមន្ត្រី

## ១_អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ១៩៩៦

**អនុក្រឹត្យ លេខ : ៣៥ អនក្រ.បក**

**ស្តីពីការបែងចែកជំពូកចំណាយឥតគ្រោងទុក នៃ**

**ថវិការដ្ឋឆ្នាំ ១៩៩៦**

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៥/០៧ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៦
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១.-** អនុញ្ញាតអោយផ្ទេរឥណទានពីជំពូក ៤១ (ចំណាយឥតគ្រោងទុក) នៃថវិការដ្ឋ ចំនួន ២.៩៧២.៥០០.០០០ រៀល (ពីរពាន់ប្រាំបួនរយចិតសិបពីរលានប្រាំរយពាន់រៀលគត់) បញ្ចូលទៅជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងផ្គូសផ្គុលតូច) របស់ក្រសួងអប់រំយុវជន និងកីឡា ។

**មាត្រា ២.-** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយ ព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

| **នាយករដ្ឋមន្ត្រីទី១** | **នាយករដ្ឋមន្ត្រីទី២** |
|---|---|
| ព្រះហស្តលេខា និងត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៦

## អនុក្រឹត្យ លេខ : ១៣១ អនក្រ.តត
## ស្តីពីការជូនមេដាយសហមេត្រី

* * *

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- **បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤**